វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ១៤ ខែ កញ្ញា ២០១៨**

---

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ធនាគារជាតិនៃកម្ពុជាបញ្ឈប់ការបង់ការប្រាក់ទៅលើទុនបម្រុងរបស់ធនាគារឯកជន
- ទឹកប្រាក់របស់ប្រទេសចិនបានជំរុញវិស័យអចលនៈទ្រព្យនៅអាស៊ីមានភាពរីកចម្រើនខ្លាំង
- ចក្ខុវិស័យពាណិជ្ជកម្មរបស់ប្រទេសចិនបានធ្លាក់ចុះ ជាមួយនឹងកំណើននៃផលិតផលក្នុងស្រុកសរុបឆ្នាំ២០១៩ ទំនងជាទទួលរងនូវផលប៉ះពាល់

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ធនាគារជាតិនៃកម្ពុជាបញ្ឈប់ការបង់ការប្រាក់ទៅលើទុនបម្រុងរបស់ធនាគារឯកជន

ធនាគារជាតិនៃកម្ពុជាបានបញ្ឈប់ការបង់ការប្រាក់ទៅលើទុនបម្រុងធនាគារឯកជនដែលខ្លួនកាន់កាប់។ ធនាគារជាតិនៃកម្ពុជាតម្រូវឲ្យធនាគារឯកជនរក្សានូវទុនបម្រុង ១២,៥ភាគរយ សម្រាប់រូបិយប័ណ្ណបរទេស និង៨ភាគរយ សម្រាប់រូបិយប័ណ្ណជាតិ (រៀល)។ មុនពេលសម្រេចគោលនយោបាយថ្មីនេះ ធនាគារជាតិនៃកម្ពុជាបានបង់ការប្រាក់ប្រចាំឆ្នាំចំនួន ៤,៥ភាគរយសម្រាប់ទុនបម្រុងរូបិយប័ណ្ណបរទេស ប៉ុន្តែមិនបានផ្តល់អត្រាការប្រាក់សម្រាប់ទុនបម្រុងដែលជារូបិយប័ណ្ណជាតិទេ។

អ្នកតំណាងនៅក្នុងឧស្សាហកម្មនេះ ដូចជានាយកគ្រប់គ្រងនៃធនាគារអេស៊ីលីដា និងប្រធានសមាគមន៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា បាននិយាយនៅក្នុងកិច្ចសម្ភាសន៍ជាមួយ ភ្នំពេញប៉ុស្តិ៍ថា៖ ការសម្រេចនេះ មិនប៉ះពាល់ធ្ងន់ធ្ងរដល់ផលចំនេញរបស់ធនាគារឯកជនទេ ព្រោះចំណូលពីការប្រាក់នៃទុនបម្រុងគឺជាផ្នែកតូចមួយនៃប្រាក់ចំណូលរបស់ធនាគារឯកជន។

### តារាងប្រចាំសប្តាហ៍៖ ថវិកាថ្នាក់ក្រោមជាតិនៃខេត្តប៉ៃលិន ឆ្នាំ ២០១៣ ដល់ ២០១៨

តារាងសប្តាហ៍នេះបង្ហាញពីសមាសភាពថវិការដ្ឋបាលថ្នាក់ក្រោមជាតិនៃខេត្តប៉ៃលិន។ ខេត្តប៉ៃលិនបានទទួលថវិកាប្រមាណជាង ៩ពាន់លានរៀល ស្មើនឹង ១,១៤ភាគរយនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិសរុបក្នុងឆ្នាំ២០១៣។ យ៉ាងណាមិញ ចំណែកថវិកាទៅខេត្តប៉ៃលិនមានការធ្លាក់ចុះមកត្រឹម 0,៦១ភាគរយ នៃថវិកាថ្នាក់ក្រោមជាតិសរុបក្នុងឆ្នាំ ២០១៦។

ការធ្លាក់ចុះនេះគឺទាក់ទងនឹងការផ្លាស់ប្តូរមូលនិធិពីរដ្ឋបាលថ្នាក់ខេត្ត ទៅឲ្យរដ្ឋបាលថ្នាក់ក្រុង ស្រុក និងថ្នាក់ឃុំសង្កាត់។ មូលនិធិ

រដ្ឋបាលថ្នាក់ឃុំសង្កាត់ នៃខេត្តប៉ៃលិនមានការកើនឡើងពី ៩៨០លានរៀលក្នុងឆ្នាំ ២០១៣ ទៅ ១.៥២០លានរៀលក្នុងឆ្នាំ២០១៦ ដែលស្មើនឹង ១១ ភាគរយ និង ១៩ភាគរយ នៃថវិការដ្ឋបាលរបស់ខេត្តប៉ៃលិន។

### ថវិកាថ្នាក់ក្រោមជាតិក្នុងខេត្តប៉ៃលិន (ប៊ីលានរៀល)




ប្រភព៖ ច្បាប់ថវិកាជាតិ ២០១៣-២០១៨

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ទឹកប្រាក់របស់ប្រទេសចិនបានជំរុញឲ្យវិស័យអចលនៈទ្រព្យនៅអាស៊ីមានភាពរីកចម្រើនខ្លាំង

រាជធានីភ្នំពេញអាចជាទីផ្សារមួយស្ថិតនៅចំកណ្តាល[ទីផ្សារអចលនៈទ្រព្យដ៏ពេញនិយមបំផុតរបស់ពិភពលោក](#) ដោយសារមានអ្នកវិនិយោគចំនួនប្រមាណ២០០នាក់ដែលលោក ស៊ី ជីនពីង ប្រធានាធិបតីចិន បានលើកទឹកចិត្តឲ្យមកទីក្រុងភ្នំពេញ ក្នុងឆ្នាំ២០១៦ ដើម្បីពង្រីកគម្រោងគនិតផ្តួចផ្តើម ខ្សែក្រវាត់មួយ និងផ្លូវមួយ។ តម្លៃខុនដូជាមធ្យមនៅរាជធានីភ្នំពេញបានកើនឡើង៦០ភាគរយ ពីឆ្នាំ២០១៣។ ការផ្គត់ផ្គង់ខុនដូត្រូវបានរំពឹងថានឹងមានការកើនឡើងទ្វេដងរហូតដល់ជាង ២០ម៉ឺនឯកតាក្នុងឆ្នាំនេះ។ ការវិនិយោគដោយផ្ទាល់ពីបរទេសបានកើនឡើងទ្វេដងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលក្នុងនោះការវិនិយោគពីប្រទេសចិនជាអ្នកនាំមុខ។ រាជធានីភ្នំពេញគឺជាឧទាហរណ៍មួយនៃការស្ទុះឡើងខ្លាំងនៃវិស័យអចលនៈទ្រព្យនៅទូទាំងអាស៊ី ដោយសារអ្នកសាងសង់ និងអ្នកប៉ាន់ប្រមាណជាជនជាតិចិនដែលមានទ្រព្យសម្បិត្តច្រើននាក់ បានធ្វើដំណើរតាមរយៈគម្រោង ផ្លូវសូត្រថ្មី ដើម្បីស្វែងរកដីធ្លីដែលត្រូវវិនិយោគ។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ចក្រវិស័យពាណិជ្ជកម្មរបស់ប្រទេសចិនបានធ្លាក់ចុះ ជាមួយនឹងកំណើននៃផលិតផលក្នុងស្រុកសរុបឆ្នាំ២០១៩ ទំនងនឹងទទួលរងផលប៉ះពាល់

កាលពីថ្ងៃសុក្រសប្តាហ៍មុន លោកប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាត្រាំ បានបង្កើនការគំរាមកំហែងរបស់លោកទ្វេដងបន្ថែមទៀតដើម្បី ដាក់ពន្ធលើការនាំចូលពីប្រទេសចិន ដោយនិយាយថា លោកត្រៀមខ្លួនរួចរាល់ដើម្បីដាក់ពន្ធទៅលើទំនិញគ្រប់យ៉ាង។ ស្ថិតិពាណិជ្ជកម្មនៃប្រទេសចិនបានចេញផ្សាយនៅសប្តាហ៍នេះ (និងបានរាយការណ៍ដោយ [Bloomberg)](#) បានបង្ហាញថា ខណៈពេលដែលអតិរេកពាណិជ្ជកម្មរវាងចិននិងសហរដ្ឋអាមេរិក បានបន្តការកើនឡើងក្នុងអំឡុងខែសីហា កំណើនការនាំចេញមានការធ្លាក់ចុះយឺតបំផុតចាប់តាំងពីខែមីនា។ ក្រុមសេដ្ឋវិទូបានរំពឹងថា អ្នកនាំចេញរបស់ចិន នឹងរងផលប៉ះពាល់យ៉ាងខ្លាំងពីសកម្មភាពរបស់សហរដ្ឋអាមេរិក ហើយអត្រាកំណើននៃផលិតផលក្នុងស្រុកសរុបរបស់ចិនក៏អាចនឹងទទួលរងផលប៉ះពាល់នេះផងដែរ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ អត្រាអតិផរណានៅប្រទេសម៉ាឡេស៊ី និងជប៉ុន ការសម្រេចចិត្តនៃអត្រាការប្រាក់របស់ធនាគារថៃ និងទិន្នន័យនៃតុល្យភាពពាណិជ្ជកម្មសម្រាប់ប្រទេសឥណ្ឌូនេស៊ី សិង្ហបុរី ជប៉ុន និងថៃ។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី ១៧ ខែកញ្ញា

- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសឥណ្ឌូនេស៊ីខែសីហា
- តុល្យភាពពាណិជ្ជកម្មនៅសិង្ហបុរីសម្រាប់ខែសីហា
- ការថែទាំ និងការលក់ទោចក្រយានយន្តនៅប្រទេសឥណ្ឌូនេស៊ីសម្រាប់ខែសីហា
- អតិផរណានៅតំបន់អឺរ៉ុបសម្រាប់ខែ សីហា

ថ្ងៃអង្គារ ទី ១៨ ខែកញ្ញា

- សន្ទស្សន៍ថ្លៃផ្ទះនៅប្រទេស អូស្ត្រាលី

ថ្ងៃពុធ ទី ១៩ ខែកញ្ញា

- អត្រាការប្រាក់របស់ប្រទេសជប៉ុន
- តុល្យភាពពាណិជ្ជកម្មជប៉ុននៅ ខែសីហា
- អតិផរណាប្រទេសម៉ាឡេស៊ីសម្រាប់ ខែសីហា
- ការសម្រេចចិត្តទៅលើអត្រាកាប្រាក់ប្រទេសថៃ
- ការចាប់ផ្តើមនូវវិស័យលំនៅដ្ឋានរបស់សហរដ្ឋអាមេរិក នៅខែ សីហា

ថ្ងៃព្រហស្បត្តិ៍ ទី ២០ ខែកញ្ញា

- ការបញ្ជាទិញរបស់តៃវ៉ាន់ សម្រាប់ខែសីហា
- ការបង្ហាញពីភាពគ្មានការងាររបស់សហរដ្ឋអាមេរិក នៅថ្ងៃទី ១៥ ខែកញ្ញា
- ការលក់ផ្ទះដែលមានស្រាប់នៅសហរដ្ឋអាមេរិក សម្រាប់ខែកក្កដា និងខែ សីហា

ថ្ងៃសុក្រ ទី ២១ ខែកញ្ញា

- សន្ទស្សន៍តម្លៃអ្នកផលិតរបស់កូរ៉េខាងត្បូង សម្រាប់ខែសីហា
- អតិផរណារបស់ប្រទេសជប៉ុនសម្រាប់ខែ សីហា
- ការវិនិយោគភាគហ៊ុនជប៉ុនដោយជនបរទេសសម្រាប់ខែកញ្ញា
- តុល្យភាពពាណិជ្ជកម្មប្រទេសថៃ នៅខែ សីហា។